នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Feb-2013, 15:58
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: បារាំង/ភាសាខ្មែរ

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ និងឧបសម្ព័ន្ធសម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយសហមេធាវីនាំមុខដើម្បីផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើព្រួសនកម្មនៃឧក្រិដ្ឋកម្មដែលមានទៅលើជនរងគ្រោះ, ដោយមានឧបសម្ព័ន្ធសម្ងាត់**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

*បញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយសហមេធាវីនាំមុខដើម្បីផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើព្រួសនកម្មនៃឧក្រិដ្ឋកម្មដែលមានទៅលើជនរងគ្រោះ, ដោយមានឧបសម្ព័ន្ធសម្ងាត់ ក*

ឡៅ ជុនធី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
គង់ ពិសី
គង់ ផល្លៈ
យុង ផានិត
សំ សុគង់
វ៉េន ពៅ
ទី ស្រីនណា
Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Philippine SUTZ
Beini YE
Elodie DULAC
Pascal AUBOIN

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង
Andrew T. CAYLEY
យ៉េត ចរិយា
William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន
អៀង សារី
នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ
Victor KOPPE

អាង ឧត្តម
Michael G. KARNAVAS

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGES

*បញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយសហមេធាវីនាំមុខដើម្បីផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើព្យសនកម្មនៃឧក្រិដ្ឋកម្ម ដែលមានទៅលើជនរងគ្រោះ, ដោយមានឧបសម្ព័ន្ធសម្ងាត់ ក*

### ១) ការរំលឹកនីតិវិធី

**១.** ថ្ងៃទី៧ កុម្ភៈ ២០១៣ អង្គជំនុំជម្រះសាលាដំបូង “អង្គជំនុំជម្រះ ” បានចេញនូវអនុសារណៈមួយ ដែលឲ្យឈ្មោះថា “សេចក្ដីជូនដំណឹងបន្ថែមពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទនៃសវនាការ[1]” នៅក្នុងសេចក្ដីជូនដំណឹងនេះ បានបង្គាប់ដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ឲ្យជូនដំណឹងដល់អង្គជំនុំជម្រះ យ៉ាងយឺតត្រឹមថ្ងៃទី២២ កុម្ភៈ ២០១៣ នូវបញ្ជីនៃដើមបណ្ដឹងរដ្ឋប្បវេណី ដែលសហមេធាវីនាំមុខសម្រេចស្នើឲ្យផ្ដល់សក្ខីកម្មលើផលប៉ះពាល់នៃឧក្រិដ្ឋកម្ម។

២. ថ្ងៃទី ៨ កុម្ភៈ ២០១៣ អង្គជំនុំជម្រះនៃតុលាការកំពូលបានសំរេចសេចក្ដីទៅលើបណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា[2] និងដែលបានគាំទ្រដោយសហមេធាវីនាំមុខ[3] ជំទាស់ សេចក្ដីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូងដែលបានច្រានចោល ដោយផ្នែក ទៅលើបណ្ដឹងសុំពង្រីកវិសាលភាពនៃការជំនុំជម្រះលើកដំបូងក្នុងសំណុំរឿងលេខ ០០២[4]។ អង្គជំនុំជម្រះនៃតុលាការកំពូល បានធ្វើមោឃៈភាពលើសេចក្ដីសម្រេច[5]

---

[1] **E236/5** អនុសារណៈនៃប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលឲ្យឈ្មោះថា “សេចក្ដីជូនដំណឹងបន្ថែមពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទនៃសវនាការ” ថ្ងៃទី ៧ កុម្ភៈ ២០១៣, កថាខណ្ឌ ៤។

[2] **E163/5/1/1** សេចក្ដីសម្រេចនៃបណ្ដឹងសារទុក្ខភ្លាមៗរបស់ហព្រះរាជអាជ្ញាទាក់ទងទៅនឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ជាមួយ ឧបសម្ព័ន ១ និង ឧបសម្ព័នសម្ងាត់ ២, ថ្ងៃទី ៧ វិច្ឆការ ២០១២។

[3] **E163/5/1/5** សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីគាំទ្រសេចក្ដីសម្រេចនៃបណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាដែលទាក់ទងទៅនឹងការពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១, នៅថ្ងៃទី ២១ វិច្ឆការ ២០១២។

[4] **E163/5/1/13** សេចក្ដីសម្រេចទៅលើបណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៃការជំនុំជម្រះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០១។

[5] **E163/8** អនុសារណៈនៃប្រធានអង្គជំនុំជម្រះសាលាដំបូងដែលឲ្យឈ្មោះថាៈ “វិញ្ញត្តនៃសេចក្ដីសម្រេចដែលកាត់សេចក្ដីលើបណ្ដឹងសហព្រះរាជអាជ្ញា ចំពោះការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មផ្សេងទៀត
នៅក្នុងក្របខណ្ឌនៃការជំនុំជម្រះលើកដំបូងនៅក្នុងសំណុំរឿងលេខ ០០២ (Doc N° E163) និង នៅក្នុងក្របខណ្ឌនៃពេលវេលាដែលបានកំណត់ សំរាប់ការដាក់នៃផ្នែកពីសេចក្ដីសម្រេចចុងក្រោយដែលទាក់ទងនឹងវិធានដែលអនុវត្ត,ថ្ងៃទី ៨ តុលា ២០១២។
*បញ្ជីនៃដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំដោយសហមេធាវីនាំមុខដើម្បីផ្ដល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើព្យសនកម្មនៃឧក្រិដ្ឋកម្មដែលមានទៅលើជនរងគ្រោះ, ដោយមានឧបសម្ព័ន្ធសម្ងាត់ ក*

នៃអង្គជំនុំជម្រះសាលាដំបូង ដោយអះអាងថា ការបំបែកសំណុំរឿងនៅក្នុងសំណុំរឿង ០០២[6] និងសេចក្តីសម្រេចដែលពាក់ព័ន្ធនៅពេលក្រោយ គឺខ្វះភាពជាក់លាក់ និងមិនមានសំអាងហេតុគ្រប់គ្រាន់នោះទេ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះនៃតុលាការកំពូលគូសបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង បានធ្វើការបំបែកនីតិវិធី និងបានកំណត់វិសាលភាពពីការជំនុំជម្រះលើកដំបូងក្នុងសំណុំរឿងនេះ ដោយមិនបានផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីដើម្បីផ្តល់យោបល់ទៅលើចំនុចទាំងនេះ។ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល គូភាគីត្រូវបានកោះហៅដោយអង្គជំនុំជម្រះសាលាដំបូង[7] ដើម្បីឆ្លើយតបនៅក្នុងសវនាការជាសាធារណៈនៅថ្ងៃទី១៨ និង ១៩ កុម្ភៈ ២០១៣ ទៅនឹងសំនួរមួយចំនួនដែលទាក់ទងដល់ការបំបែសំណុំរឿង និងផលវិបាកនៃការបំបែកសំណុំរឿងនេះ។

៣. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់ជូននូវបញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីដែលភ្ជាប់ជាឧបសម្ព័ន្ធនៃពាក្យសុំនេះ ដែលសហមេធាវីនាំមុខយល់ឃើញថាសក្ខីកម្មរបស់អ្នកទាំងនេះក្នុងសវនាការ មានភាពចាំបាច់នៅក្នុងក្របខណ្ឌនៃសវនាការពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ។ ក៏ប៉ុន្តែ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រក្សាទុកសិទ្ធិផ្លាស់ប្តូរ បញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណី នៅពេលណាដែលវិសាលភាពនៃការជំនុំជម្រះត្រូវបានកំណត់។

២) ការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណី

---

[6] **E124** បទបញ្ញត្តិស្តីពីការបំបែកអង្គហេតុដោយអនុវត្តនៃវិធាន ៨៩ស្ទួន នៃបទបញ្ជាផ្ទៃក្នុង, ២២ កញ្ញា ២០១១។

[7] **E163/5/1/13/1** អនុសារណៈនៃប្រធានអង្គជំនុំជម្រះសាលាដំបូងដែលឲ្យឈ្មោះថា “ការចង្អុលបង្ហាញទៅគូភាគីបន្ទាប់ពីសេចក្តីសម្រេចអង្គជំនុំជម្រះនៃតុលាការកំពូលលើបណ្តឹងសារទុក្ខភ្លាមៗរបស់ព្រះរាជអាជ្ញាទៅលើការជំនុំជម្រះ សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងទាក់ទងវិសាលភាពសំណុំរឿង ០០២/០១ ១២(E163/5/1/13)”, ថ្ងៃទី ១២ កុម្ភៈ ២០១៣ និង **E264** អនុសារណៈនៃប្រធានអង្គជំនុំជម្រះសាលាដំបូង ឲ្យឈ្មោះថា: សំណួរបន្ថែមដល់គូភាគីបន្ទាប់ពីសវនាការ ថ្ងៃទី ១៨ កុម្ភៈ ២០១២ ដោយស្របពីសេចក្តីសម្រេចអង្គជំនុំជម្រះនៃតុលាការកំពូលលើបណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៃការជំនុំជម្រះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ (E163/5/1/13), ១៩ កុម្ភៈ ២០១៣។

៤. សហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីបានពិភាក្សាជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានជ្រើសរើសយកដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០រូប ដើម្បីធ្វើសក្ខីកម្មជាក់លាក់ទៅលើព្យសនកម្មនៃឧក្រិដ្ឋកម្មដែលកើតឡើង។

៥. ដូចដែលបានបង្ហាញដោយអង្គជំនុំជម្រះពីមុន[8] មួយសប្តាហ៍នៃសវនាការ (មានន័យថា បួនថ្ងៃនៃសវនាការ) ដើម្បីលើកឡើងពី "កំណត់សំគាល់ដែលពាក់ព័ន្ធនឹងការឈឺចាប់ថ្លែងដោយដើមបណ្តឹងរដ្ឋប្បវេណី"[9]។

៦. ដោយសហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានពិចារណាពីភាពចាំបាច់ មិនឱ្យអូសបន្លាយហួសហេតុនូវពេលវេលានៃការជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើជាថ្មីនូវសំណើររបស់ពួកគេដែលបានលើកនៅ នៅពេលកិច្ចប្រជុំរៀបចំតុលាការ[10] ឱ្យឯកភាពផ្តល់បន្ថែមរយៈពេលដល់ដើមបណ្តឹងរដ្ឋប្បវេណីសំរាប់សវនាការ។ យ៉ាងហោចណាស់ សហមេធាវីនាំមុខស្នើរសុំដល់អង្គជំនុំជម្រះ យល់ស្របឱ្យសហមេធាវី ចំនួនមួយថ្ងៃបន្ថែមនៃសវនាការ។ ថ្ងៃបន្ថែមនៃសវនាការនេះ អនុញ្ញាតឱ្យសក្ខីកម្មនៃអ្នកជំនាញពីររូបដែលមានសារៈសំខាន់សំរាប់បង្ហាញពី អ្វីដែលបានជួបប្រទះ លើការប៉ះពាល់ពីឧក្រិដ្ឋកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ។

---

[8] **E236/5** អនុស្សារណៈនៃប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលឱ្យឈ្មោះថា "ការបន្ថែមពត៌មានដែលទាក់ទងនឹងការរៀបចំកម្មវិធីសវនាការនៃការជំនុំជម្រះ, ថ្ងៃទី៧ កុម្ភៈ ២០១៣, កថាខណ្ឌ ២។

[9] **E218** អនុស្សារណៈនៃប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលឱ្យឈ្មោះថា "ការរៀបចំនៃការប្រជុំ ពីលើកឡើងដោយទៅតាមកម្មវិធី ដំណាក់កាលដែលមាននៅនៃការជំនុំជម្រះលើកដំបូងក្នុងក្របខណ្ឌនៃសំណុំរឿងលេខ ០០២ និង ពីដាក់ឱ្យប្រើប្រាស់វិធានការផ្សេងដែលនាំឱ្យមានប្រសិទ្ធិភាពនៃកិច្ចពិភាក្សា, ថ្ងៃទី ៣ កក្កដា ២០១២, កថាខណ្ឌ ១៨។

[10] **E1/114.2** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសវានាការរៀបចំតុលាការ សម្ងាត់-អសាធារណៈ,ថ្ងៃទី ២៧ កក្កដា ២០១២, កថាខណ្ឌ ៦, បន្ទាត់ទី ២២ ដល់២៥ និង កថាខណ្ឌ ៧ បន្ទាត់ទី ១ ដល់ ១៧។

៧. សហមេធាវីនាំមុខគូសបញ្ជាក់ម្តងទៀតថា ប្រសិនបើការកាត់បន្ថយបញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីត្រូវតម្រូវឲ្យមាន វិធានផ្ទៃក្នុងមិនបានបញ្ញត្តិថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងកែប្រែ បញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីនៅពេលក្រោយឡើយ។

៨. ដូចដែលយើងបានថ្លែងនៅក្នុងការស្នើសុំមុននេះ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា បញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែកែប្រែ "សហមេធាវីនាំមុខ ទាមទារថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកែប្រែបញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីដោយខ្លួនឯង។ សហមេធាវីនាំមុខនឹងគិតគូរទាំងការប្រឈមនឹងពេលវេលាដែលជំនុំជម្រះមាន និងមូលហេតុជាក់ស្តែង ដែលនាំឲ្យមានការកាត់បន្ថយបញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីនេះ។ ទោះយ៉ាងនេះក្តី សហមេធាវីនាំមុខ គឺអាចមានសមត្ថភាពបំផុតក្នុងការការកែប្រែបញ្ជីរបស់ខ្លួន ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលមានព័ត៌មានពាក់ព័ន្ធ និងមានតំលៃជាភស្តុតាងបំផុត អាចនឹងត្រូវបានស្តាប់ដោយអង្គជំនុំជម្រះ"[11]។

៣) សំណើរ៖

៩. ដោយមូលហេតុខាងលើនេះ សហមេធាវីនាំមុខ សូមស្នើរសុំដល់អង្គជំនុំជម្រះ ៖

១) ជាចម្បង៖

- បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើរសុំនៅក្នុង ឧបសម្ព័ន្ធ ក ក្នុងបញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវស្តាប់ក្នុងកំឡុងពេលសវនាការលើព្យសនកម្ម។
- យ៉ាងហោចណាស់ យល់ស្របផ្តល់រយៈពេលបន្ថែមមួយថ្ងៃសំរាប់ដាក់បន្ថែមអ្នកជំនាញពីររូបទៀត។

---

[11] **E218/4** បញ្ជីដែលបានដាក់ដោយសហមេធាវីនាំមុខ នៃដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងក្របខណ្ឌនៃកិច្ចពិភាក្សាដែលដាក់លើដំណាក់កាលទី ១ និង ទី ២ នៃការជម្លៀសប្រជាជនក្នុងសំណុំរឿង ០០២/០១ ដែលបានមាន ឧបសម្ព័នសម្ងាត់ ១, កថាខណ្ឌ ១៨, ថ្ងៃទី ២២ កក្កដា ២០១២។
*បញ្ជីនៃដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយសហមេធាវីនាំមុខដើម្បីផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើព្យសនកម្មនៃឧក្រិដ្ឋកម្មដែលមានទៅលើជនរងគ្រោះ, ដោយមានឧបសម្ព័ន្ធសម្ងាត់ ក*

២) ជាបន្ទាប់បន្សំ

- រក្សាទុកឲ្យសហមេធាវីនាំមុខនូវលទ្ធភាពការកែប្រែបញ្ជីដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវកោះហៅឲ្យផ្ដល់សក្ខីកម្មលើព្យសនកម្ម។
- ផ្ដល់លទ្ធភាពឲ្យសហមេធាវីនាំមុខបំពេញបញ្ជីដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលដែលវិសាលភាពនៃការជំនុំជម្រះត្រូវបានកំណត់។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ២២ កុម្ភៈ ២០១៣ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | ភ្នំពេញ | |